**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានព័ត៌មាន**

# សេចក្តីជូនព័ត៌មាន

តបតាមការអញ្ជើញរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវ **សេក្ខ ហាស៊ីណា** (Sheikh Hasina) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស នឹងដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៧ ។

ក្នុងអំឡុងពេលទស្សនកិច្ច លោកជំទាវ សេក្ខ ហាស៊ីណា នឹងចូលគ្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង ។

លោកជំទាវ ក៏នឹងចូលជួបសម្តែងការគួរសមដាច់ដោយឡែកពីគ្នា ជាមួយ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ហើយនឹងមានជំនួបទ្វេភាគីជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផងដែរ។ បន្ទាប់មក នាយករដ្ឋមន្ត្រីទាំងពីរ នឹងអញ្ជើញធ្វើជាអធិបតី ក្នុងពិធីចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការមួយចំនួន នឹងបន្តដោយការប្រកាសព័ត៌មានរួមគ្នា។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសកម្ពុជា លោកជំទាវ សេក្ខ ហាស៊ីណា នឹងអញ្ជើញដាក់កម្រងផ្កានៅវិមានឯករាជ្យ គោរពវិញ្ញាណក្ខន្ធវីរបុរស-វីរនារីកម្ពុជាដែលបានពលីក្នុងសង្គ្រាម គោរពព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រកម្ពុជា ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះបរមរតនកោដ្ឋ ទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងចូលរួមជាអធិបតីក្នុងកិច្ចសន្ទនាធុរកិច្ច រៀបចំដោយសភាពាណិជ្ជកម្មកម្ពុជា ។

គួរកត់សម្គាល់ផងដែរថា លោកជំទាវ សេក្ខ ហាស៊ីណា នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ធ្លាប់បានបំពេញទស្សនកិច្ចផ្លូវការលើកទីមួយ នៅកម្ពុជា ស្របពេលនៃការចូលរួមរបស់លោកជំទាវ ក្នុងសន្និសីទសមាគមសភាអាស៊ីសម្រាប់សន្តិភាព នៅទីក្រុងភ្នំពេញ កាលពីខែមករា ឆ្នាំ២០០១។

ដំណើរទស្សនកិច្ចផ្លូវការរបស់លោកជំទាវ សេក្ខ ហាស៊ីណា នៅព្រះរាជាណាចក្រកម្ពុជា ឆ្លុះបញ្ចាំងពីការពង្រឹងចំណងមិត្តភាព ដែលប្រទេសទាំងពីរបានថែរក្សាជាច្រើនឆ្នាំកន្លងមក និងធ្វើឲ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការទ្វេភាគីដែលមានស្រាប់រវាងកម្ពុជា និងបង់ក្លាដែស។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh